# ភស្តុតាងនៃការប្រើប្រាស់ដំរីក្នុងសឹកសង្គ្រាម
## (ចម្លាក់និងសិលាចារឹក)

ដំរី ជាសត្វមួយដែលមានភាពជិតស្និទ្ធខ្លាំងជាមួយមនុស្ស ទាំងការរស់នៅ និងកិច្ចការស្ថាបនាសំណង់នានា។ ដ្បិតគេគិតថាទោះបីដំរីជាសត្វព្រៃកាចសាហាវនិងមានកម្លាំង តែគេផ្សាយផ្សាំងសត្វនេះយកមកប្រើប្រាស់ឱ្យមានចរឹកស្លូតបូត និងផាយប្រើប្រាស់សម្រាប់ការផារធ្ងន់ៗ មិនតែប៉ុណ្ណោះនៅសម័យបុរាណបានប្រើប្រាស់សត្វដំរីប្រើប្រាស់ក្នុងសឹកសង្គ្រាម ដូចមានបង្ហាញតាមរយៈចម្លាក់នៅតាមជញ្ជាំងប្រាសាទមួយចំនួន និងបង្ហាញតាមរយៈសិលាចារឹកទៀតផង។

ជាទូទៅចម្លាក់ទាក់ទងនឹងសត្វដំរីនៅក្នុងសិល្បៈខ្មែរ យើងឃើញមានតាំងពីស.វ.ទី៧មកម្ល៉េះ ដូចឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំ។ ប៉ុន្តែ ចម្លាក់ទាំងនោះសុទ្ធសឹងបង្ហាញដំរីដែលជាយានជំនិះរបស់ព្រះឥន្ទ្រប៉ុណ្ណោះ ពោល គឺដំរីដែលកើតចេញពីការកូរសមុទ្រទឹកដោះដែលមានឈ្មោះថា "ឰរ័ត" (រូបលេខ១)។[១] បន្ទាប់មក នៅស.វ.ទី១០ យើងឃើញមានការបង្ហាញចម្លាក់ដំរីស្រោចទឹកឱ្យព្រះនាងលក្ស្មី ដូចឃើញនៅលើហោជាងប្រាសាទបន្ទាយស្រី (រូបលេខ២)។[2] [២]ចាប់ពីស.វ.ទី៩-១៣មក យើងឃើញគេនិយមធ្វើបដិមារូបដំរីដាក់នៅតាមជ្រុងប្រាសាទក្នុងគំនិតដែលយល់ថា ដំរីគឺជាសត្វមួយដែលជាឆ្មាំនៅចាំយាមទីស្ថានរបស់អាទិទេពនៅភ្នំព្រះសុមេរុ ដូចឃើញនៅប្រាសាទបាគង ប្រាសាទដំរីនៅកោះកេរ ប្រាសាទមេបុណ្យខាងកើត ប្រាសាទភិមានអាកាស ក្រុមប្រាសាទព្រះពិធូរ ប្រាសាទដំរីនៅបាកាណ ជាដើម (រូបលេខ៣)។ ជាងនេះទៀត ក្នុងសម័យស.វ.ទី១២មក ចម្លាក់ដំរីដែលទាក់ទងនឹងរឿងរ៉ាវព្រះពុទ្ធសាសនាក៏មានច្រើនគួរសមដែរ ដូចឃើញនៅប្រាសាទបាលីលេយ្យ (រូបលេខ៤)។ ចម្លាក់ដំរីដែលគួរកត់សម្គាល់មួយទៀតនោះ គឺនៅព្រលានជល់ដំរី ដែលយើងឃើញចម្លាក់ទាក់ទងនឹងដំរីច្រើនណាស់ ហើយទីនោះទំនងជាកន្លែងផ្សាំងដំរី ឬហ្វឹកហាត់ដំរី ឬជល់ដំរី ឬជាកន្លែងធ្វើកិច្ចទាក់ទងនឹងសត្វដំរីដ៏សំខាន់នៅសម័យបុរាណ (រូបលេខ៥)។

ដោយឡែក ចម្លាក់សត្វដំរីដែលយើងគិតថាអាចទាក់ទងនឹងការយកដំរីប្រើប្រាស់ក្នុងសឹកសង្គ្រាម យើងឃើញចាប់ផ្តើមមាននៅស.វ.ទី១២មកដូចជា ចម្លាក់នៅជញ្ជាំងប្រាសាទអង្គរវត្ត ប្រាសាទបន្ទាយឆ្មារ ប្រាសាទបាយ័នៗលៗ នៅជញ្ជាំងប្រាសាទអង្គរវត្ត សិល្បករបានបង្ហាញ

---

[១]សូមមើលអត្ថបទរបស់លោក សុខ កែវសុវណ្ណារ៉ា ផ្សាយក្នុងគេហទំព័រ **AMS Khmer Civilization,** https://ams.com.kh/khmercivilization/detail/505

[២]Roveda 2005: 72.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

ចម្លាក់ក្បួនដង្ហែទ័ពចេញច្បាំង ដែលអ្នកដឹកនាំគង់ឈរនៅលើសត្វដំរី ដោយព្រះហស្តកាន់ផ្គាក់ជាអាវុធ (ទំនងជាព្រះបាទសូរ្យវរ្ម័នទី២ ដ្បិតយើងឃើញមានហែរហមដោយក្ងស់ជាច្រើន) (រូបលេខ២៦)។ រីឯនៅជញ្ជាំងប្រាសាទបាយ័នវិញ យើងឃើញមានរូបមេទ័ពអង្គុយនៅលើដំរីក្នុងសមរភូមិច្រើនគួរសម ហើយចម្លាក់មួយដែលគួរឱ្យកត់សម្គាល់នោះគឺ ទំនងជាមេទ័ពម្នាក់ឈរលើសត្វដំរីបាញ់ព្រួញសំដៅទៅខ្មាំងសត្រូវ (រូបលេខ២៧)។ នៅជញ្ជាំងប្រាសាទបន្ទាយឆ្មារឯណោះវិញ ក៏មានបង្ហាញចម្លាក់មេទ័ពដឹកនាំទ័ពចេញច្បាំងអង្គុយនៅលើសត្វដំរី ដោយយកដៃចង្អុលទៅកាន់អ្វីមួយ (រូបលេខ២៨) និងមានចម្លាក់មួយផ្ទាំងទៀតបង្ហាញមេទ័ពម្នាក់អង្គុយលើសត្វដំរី ដោយមានដៃកាន់ព្រួញបម្រុងនឹងបាញ់ (រូបលេខ២៩)។

ចំពោះនៅក្នុងសិលាចារឹកវិញ ពាក្យ "**ដំរី**" គេបានកត់ត្រាអក្ខរាវិរុទ្ធខុសៗគ្នាដូចជា **តំរ្វិយ** (K.654) **តំម្វ** (K.388) **តំរេ** (K.9) **តំរេយ្យ** (K.257) ដែលភាគច្រើនរៀបរាប់អំពីអំណោយជាសត្វដំរីរបស់ស្តេច មន្ត្រី ឬអ្នកមានសទ្ធាបុណ្យថ្វាយដល់ទេវស្ថាន។[៣] នៅស.វ.ទី៩ ព្រះរាជាខ្មែរមួយអង្គគឺព្រះបាទជ័យវរ្ម័នទី៣ ជាស្តេចដែលចូលចិត្តទាក់សត្វដំរីខ្លាំងណាស់ ដែលយើងអាចដឹងបានតាមរយៈសិលាចារឹកមួយចំនួនដូចជា សិលាចារឹកប្រាសាទគោកឬស្សី (K.175) រៀបរាប់ថា៖ "*ព្រះមហាក្សត្រយាងទៅកាន់វិស្ណុលោក (ព្រះបាទជ័យវរ្ម័នទី៣) បានស្តេចយាងទៅចាប់ដំរីមួយក្បាលនៅព្រំប្រទល់ព្រៃព្រះកន្ទោង*[4៤], សិលាចារឹកប្រាសាទគោកចក (K.521) រៀបរាប់ថា៖ "*មហាសករាជឆ្នាំ៧៧២ ព្រះករុណាស្រីជ័យវម៌្មទេវ ស្តេចយាងទៅកាន់វិស្ណុលោក ត្រូវជាបុត្រព្រះបាទបរមេស្វរ បានមកគង់នៅភូមិព្រៃស្វាដើម្បីចាប់សត្វដំរីមួយក្បាលទុក តែដំរីនោះបានរត់រួចចូលទៅក្នុងព្រៃវិស្ណុគ្រាម ទ្រង់ក៏ផ្ទុំនៅទីនោះមួយរាត្រី ហើយព្រះអង្គក៏បន់ស្រន់ឱ្យរកដំរីនោះឃើញវិញ ក្នុងយប់នោះព្រះអង្គទ្រង់ព្រះសុបិនឃើញព្រះកម្រតេងអញវិស្ណុរាមួយ មានបន្ទូលមកកាន់ទ្រង់ថា កាលណាឯងកសាងរូបអញនិងខិតខំគោរពអញដោយភក្តីភាព អញនឹងឱ្យឯងឃើញដំរីនោះវិញជាមិនខាន លុះព្រឹកឡើងស្តេចក៏បានឃើញដំរីនោះពិតប្រាកដមែន ក៏បានបញ្ជាឱ្យគេស្ថាបនារូបសកព្រាហ្មណ៍ ហើយធ្វើពិធីបុណ្យឆ្លងនៅទីនោះដោយដាក់ឈ្មោះថា "វិស្ណុគ្រាម" និងបានថ្វាយដីមួយកន្លែងនៅជិតដីរបស់ផ្លូវប្រាង្គ*។[5៥] ទោះបីជាយ៉ាងណា សិលាចារឹកទាំងអម្បាលម៉ានដែលបានរៀបរាប់ខាងលើ បានបង្ហាញឱ្យឃើញថា ព្រះរាជាខ្មែរមួយអង្គទ្រង់សព្វព្រះរាជ

[៣] Saveros Pou 1992: 212-213.

[៤] Cœdès 1954: 174.

[៥] Cœdès 1952: 67-69.

ហាឫទ័យក្នុងការទាក់សត្វដំរី និងអ្នកមានសទ្ធាបុណ្យតែងថ្វាយសត្វដំរីដល់ប្រាសាទ ប៉ុន្តែមិនបានបញ្ជាក់ឱ្យយើងឃើញអំពីកស្តុតាងនៃការប្រើប្រាស់សត្វដំរីក្នុងសឹកសង្គ្រាមឡើយ។ ទោះបីយ៉ាងនេះក្តី មានសិលាចារឹកដ៏សំខាន់មួយចារនៅស.វ.ទី៧ ដែលជាឧទាហរណ៍មួយបញ្ជាក់ឱ្យយើងឃើញថា ព្រះរាជាខ្មែរនៅសម័យបុរាណបានបញ្ជាឱ្យគេចាប់សត្វដំរីមកផ្សាំង ដើម្បីទុកប្រើប្រាស់ក្នុងសមរភូមិប្រយុទ្ធ។ សិលាចារឹកនោះចារនៅមេទ្វារប្រាសាទភ្នំហាន់ជ័យ ខេត្តកំពង់ចាម ចុះបញ្ជីលេខ K.81 ដែលគាថាខាងលើមករៀបរាប់ពោលសរសើរពីគុណលក្ខណៈសម្បត្តិជាច្រើនរបស់ព្រះបាទភវវរ្ម័នទី១ (គ.ស.៥៩៨-៦០៦) ក្នុងកិច្ចការគ្រប់គ្រងជាតិកាលទ្រង់ជាព្រះមហាក្សត្រនៅជំនាន់នោះ ហើយនៅគាថាទី៥ បានរៀបរាប់ថា៖

*"និត្យទានបយស្សិក្ត កការិ ឯវ មតង្គជាគានិ*
*អាត្មានុការាទិ ឥវ យះ សមរាយ សមគ្រហិត"។*

ប្រែសម្រួលថា[៦]៖

***"ព្រះអង្គបានចាប់សត្វដំរីសាដើម្បីប្រើការក្នុងសមរភូមិ ជាដំរីដែលមានប្រមោយផ្សើម ដោយទឹកដម ហើយហាក់បីដូចជាធ្វើតម្រាប់តាមហត្ថា ដែលផ្សើមដោយទឹក មន្តនាពេលធ្វើអំណោយទាននានា"។***

ជារួមមក នៅសម័យបុរាណចាប់តាំងពីរវាងស.វ.ទី៦មក ព្រះរាជាខ្មែរជាច្រើនអង្គ ព្រមទាំងមេទ័ព ពិតជាបានប្រើប្រាស់សត្វដំរីក្នុងសឹកសង្គ្រាមពិតប្រាកដមែន ដោយយើងអាចមើលឃើញកស្តុតាងតាមរយៈសិលាចារឹកនៅស.វ.ទី៧ (សិលាចារឹកភ្នំហាន់ជ័យ) និងមើលឃើញតាមតាមរយៈចម្លាក់ជាច្រើនផ្ទាំង ជាពិសេសចម្លាក់ទាក់ទងនឹងក្បួនព្រះរាជាឬមេទ័ពគង់នៅលើសត្វដំរីដង្ហែទ័ពចេញច្បាំង នៅស.វ.ទី១២ (ប្រាសាទអង្គរវត្ត) និងចម្លាក់មេទ័ពអង្គុយនិងឈរនៅលើសត្វដំរីក្នុងសមរភូមិប្រយុទ្ធជាមួយខ្មាំងសត្រូវ ដូចឃើញនៅចម្លាក់ប្រាសាទបាយ័ន និងប្រាសាទបន្ទាយឆ្មារដែលបានបង្ហាញខាងលើស្រាប់។ ចម្លាក់ និងសិលាចារឹកដែលបង្ហាញដោយសង្ខេបនេះ បង្ហាញឱ្យឃើញពីភាពប៉ិនប្រសប់របស់បុព្វបុរសខ្មែរក្នុងការផ្សាំងសត្វដំរីព្រៃដ៏កាចសាហាវយកមកប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងប្រើប្រាស់ក្នុងសឹកសង្គ្រាមជាមួយសត្រូវដើម្បីការពារជាតិមាតុភូមិកម្ពុជា៕

[៦] *ប្រែសម្រួលដោយ លោក កំ វណ្ណារ៉ា;* Barth 1885.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៖ ចម្លាក់រូបព្រះឥន្ទ្រជិះដំរីលម្អនៅលើផ្តែរទ្វារប្រាសាទនៅតំបន់ប្រាសាទសំបូរព្រៃគុក (ស.វ.ទី៧)



រូបលេខ២៖ ចម្លាក់ដំរីស្រោចទឹកព្រះនាងលក្ស្មី ហោជាងប្រាសាទបន្ទាយស្រី ស.វ.ទី១០ រូបថត៖ កុំ រតនៈពិសិដ្ឋ



រូបលេខ៣៖ ចម្លាក់បដិមាសត្វដំរីតម្កល់នៅជ្រុងប្រាសាទដំរី តំបន់បាកាណ ចុងស.វ.ទី១២ ដើមស.វ.ទី១៣

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ២៨៖ ចម្លាក់ក្នុងរឿងពុទ្ធប្រវត្តិនៅប្រាសាទបាលិលេយ្យ ស.វ.ទី១២ រូបថត៖ កុំ រតនៈពិសិដ្ឋ*



*រូបលេខ២៩៖ ចម្លាក់ដំរីនៅជញ្ជាំងព្រលានជល់ដំរី ចុងស.វ.ទី១២ ដើមស.វ.ទី១៣ រូបថត៖ កុំ រតនៈពិសិដ្ឋ*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៦៖ ចម្លាក់ព្រះរាជាឬមេទ័ពឈរលើសត្វដំរីដង្ហែក្បួនទ័ពនៅជញ្ជាំងប្រាសាទអង្គរវត្ត ស.វ.ទី១២
រូបថត៖ កុំ រតនៈពិសិដ្ឋ



រូបលេខ២៧៖ ចម្លាក់មេទ័ពឈរលើសត្វដំរីបាញ់ព្រួយក្នុងសមរភូមិនៅជញ្ជាំងប្រាសាទបាយ័ន្ត ស.វ.ទី១៣
រូបថត៖ កុំ រតនៈពិសិដ្ឋ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៨៖ ចម្ងាក់មេទ័ពអង្គុយលើដំរីបាញ់នៅជញ្ជាំងប្រាសាទបន្ទាយឆ្មារ ស.វ.ទី១៣*
*រូបថត៖ លាក់ ស៊ីផាន់ណា*



*រូបលេខ៩៖ ចម្លាក់មេទ័ពអង្គុយលើដំរីបាញ់បម្រុងបាញ់ព្រួញនៅជញ្ជាំងប្រាសាទបន្ទាយឆ្មារ ស.វ.ទី១៣*
*រូបថត៖ លាក់ ស៊ីផាន់ណា*

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

# ឯកសារយោង

*សុខ កែវសុវណ្ណារ៉ា*

២០២១, "ដំរីក្បាលបីឰរ៉ត" ផ្សាយក្នុងគេហទំព័រ AMS Khmer Civilization, https://ams.com.kh/khmercivilization/detail/505

**Barth, A.**

1885, *Inscription Sanskrities du Cambodge,* Paris.

**Coedès, G.**

1952, '*Inscription du Cambodge,* Vol 4, Hanoi.

1954, '*Inscription du Cambodge,* Vol 6, Hanoi.

**Roveda, V.**

2005, *Image of the God,* River Books: Bangkok.

**Saveros Pou**

1991-1992, '*Dictionnaire Vieux Khmer-Français-Anglais,* Paris.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION